**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជន ជាពិសេសពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃទាំងអស់ឱ្យបានជ្រាបថា ថ្មីៗនេះអាជ្ញាធរថៃបានចេញសេចក្តីជូនដំណឹងដល់ប្រជាពលរដ្ឋដែលរស់នៅតំបន់ចំនួន ១៦ នៅក្បែរប្រភពទឹក ជាពិសេសនៅតាមបណ្តោយទន្លេចៅប្រះយ៉ាក្នុងទីក្រុងបាងកក ឱ្យបង្កើនការប្រុងប្រយ័ត្នខ្ពស់ និងរៀបចំទុកដាក់សម្ភារប្រើប្រាស់នៅកន្លែងមានសុវត្ថិភាព ដោយសារតែកម្រិតទឹកទន្លេចៅប្រះយ៉ាអាចកើនឡើងខ្ពស់ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤ខាងមុខ។ គិតត្រឹមព្រឹកថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤នេះ ក្រសួងមិនទាន់ទទួលបានព័ត៌មានថាមានពលករកម្ពុជារងគ្រោះ ឬមានបញ្ហាដោយសារគ្រោះទឹកជំនន់នេះនៅឡើយទេ។

ក្រសួងបាននិងកំពុងយកចិត្តទុកដាក់តាមដានស្ថានការណ៍វិវត្តន៍នៃកម្រិតទឹកទន្លេចៅប្រះយ៉ា ដោយបានធ្វើការយ៉ាងជិតស្និទ្ធជាមួយស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ និងទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ ដើម្បីធានាថាពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅតាមបណ្តោយទន្លេចៅប្រះយ៉ាក្នុងទីក្រុងបាងកក និងតំបន់ផ្សេងៗទៀត ទទួលបានការយកចិត្តទុកដាក់ និងស្ថិតនៅទីកន្លែងមានសុវត្ថិភាព។

ក្រសួងសូមអំពាវនាវដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅតាមបណ្តោយទន្លេចៅប្រះយ៉ាក្នុងទីក្រុងបាងកក និងតំបន់ផ្សេងៗទៀត បង្កើនការប្រុងប្រយ័ត្នខ្ពស់ និងបន្តយកចិត្តទុកដាក់តាមដានស្ថានការណ៍ព្រមទាំងអនុវត្តតាមការណែនាំរបស់អាជ្ញាធរថៃឱ្យបានខ្ជាប់ខ្ជួន។

ក្នុងករណីទទួលរងផលប៉ះពាល់ ឬទទួលបានព័ត៌មានអំពីពលករកម្ពុជាដែលរងផលប៉ះពាល់ សូមទំនាក់ទំនងអនុព័ន្ធការងារ (Facebook Page: https://www.facebook.com/la.in.thailand ឬ ទូរសព្ទលេខ ០៩៤ ០៩២ ៥៩០៥ ឬ ០៩៤ ៤១៦ ៥៥១៨) ឬ ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ (ទូរសព្ទលេខ ០៩២ ៨០៥០ ៥៦១) ឬ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ប្រព័ន្ធ Hotline លេខ ១២៨៦ ឬ ១២៩៧ ឬ ទូរសព្ទលេខ +៨៥៥ ៩៧ ៩២០ ២០២៣) ឬ ក្រុមតេលេក្រាម "សម្រាប់ ពលករទេសន្តរប្រវេសន៍" (https://t.me/KhmerMigrantWorker) ដែលអាចភ្ជាប់តាមរយៈការស្កេន QR Code ខាងក្រោម។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤

ក្រុមតេលេក្រាម

"សម្រាប់ ពលករទេសន្តរប្រវេសន៍"